ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងរដ្ឋប្បវេណីលេខ ៥៣
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១
សាលក្រមលេខ ៥៦/០៧ ( ខ )
ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

# លិខិតសាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១
ដោយមានសមាសភាពជំនុំជម្រះមានដូចតទៅ

**ចៅក្រម**

លោក [redacted] ជាអនុប្រធានសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជី**

លោកស្រី [redacted] ជាក្រឡាបញ្ជី

-បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ ៥៣ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ រវាង ៖

-ដើមចោទ:

ឈ្មោះ [redacted] ស្រីពូន ភេទស្រី កើតថ្ងៃទី១៤.០២.១៩៩០ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]

ដោយមានលោក [redacted] លោកស្រី [redacted] លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ [redacted]

-ចុងចម្លើយ:

ឈ្មោះ [redacted] សារិន ភេទប្រុស កើតថ្ងៃទី០៣.០៨.១៩៩០ មានអាសយដ្ឋានបច្ចុប្បន្ន [redacted]

## ១.អង្គហេតុ និងចំណុចវិវាទ

១.១.សាលក្រមដែលដើមចោទបានទាមទារមាន

-សុំលែងលះ

-សុំបែងចែកកូនៗ

១.២.ការពន្យល់ត្រួសៗអំពីរឿងក្តី

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ឈ្មោះ [redacted] ស្រីពូន បានអះអាងថា ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ១១៣ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ របស់មន្ត្រីអត្រានុកូលដ្ឋាន។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នានេះ គឺមានកូនម្នាក់ឈ្មោះ [redacted] ភិសុទ្ធ ភេទប្រុស កើតថ្ងៃទី១៤.០១.២០១៩ ខ្លួនស្នើសុំចិញ្ចឹម។ ដោយឡែកទ្រព្យសម្បត្តិ និងបំណុលរួមគឺគ្មានឡើយ។ ក្នុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ខ្លួននិងប្តីតែងតែឈ្លោះប្រកែកគ្នា រស់នៅមិនចុះសម្រុងនឹងគ្នា ដោយមិនអាចរស់នៅជាមួយគ្នាតទៅទៀតបាន ទើបខ្លួនបានដាក់ពាក្យបណ្តឹងមកកាន់តុលាការ ដើម្បីឱ្យតុលាការចេញសាលក្រមដូចការទាមទាររបស់ខ្លួន។

១.៣.សេចក្តីថ្លែងការណ៍របស់គូភាគី

-សេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] ស្រីពូន៖ ខ្លួនសូមរក្សាការទាមទារ ដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ ទុកនៅដដែល។

ខ្លួនសូមបញ្ជាក់ថា ខ្លួននិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ លេខ ១១៣ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍នេះ ខ្លួននិងចុងចម្លើយតែងតែឈ្លោះប្រកែកគ្នា រស់នៅអស់មនោសញ្ចេតនា ដែលមិនអាចរស់នៅជាមួយគ្នាបន្តទៀតបាន។ ក្នុងការរួមរស់នៅជាមួយគ្នា ខ្លួននិងចុងចម្លើយមានកូនម្នាក់ឈ្មោះ [redacted] ភិសុទ្ធ ភេទប្រុស កើតថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ តាមសំបុត្រកំណើត លេខ ២៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩។ ខ្លួនសូមសិទ្ធិចិញ្ចឹម និងមើលថែកូននេះ ស្នើសុំឱ្យចុងចម្លើយបង់ប្រាក់អាហារកិច្ចទៅតាមលទ្ធភាព។ ចំពោះទ្រព្យសម្បត្តិរួម ខ្លួននិងចុងចម្លើយ មិនមានទ្រព្យសម្បត្តិរួមឡើយ។

-សេចក្តីថ្លែងការណ៍របស់លោក [redacted] លោកស្រី [redacted] លោក [redacted] និងលោក [redacted]៖ ខ្លួនឯកភាពនឹងសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួន។

-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted]៖ អវត្តមានតែបានបញ្ជូនដីកាកោះរួចហើយ។

១.៤.ចំណុចវិវាទ និង ចំណុចដែលគ្មានវិវាទ

-ចំណុចដែលគ្មានវិវាទ: គ្មាន។

-ចំណុចវិវាទ: ការលែងលះ និងកូន។

## ២.ផ្នែកសំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងការពិនិត្យភស្តុតាង នៅក្នុងសំណុំរឿង [illegible] ការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖



Scanned with CamScanner

២.១.ស្តីពីការទាមទារទី ១ : ការលែងលះ

-តាមការអះអាងរបស់ដើមចោទ ឃើញថា ខ្លួននិងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ កាលពីឆ្នាំ២០១៥ ហើយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ប្រាកដមែន តាមសំបុត្រអាពាហ៍ពិពាហ៍ លេខ ១១៣ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥។

-ដើមចោទអះអាងថា ខ្លួន និងចុងចម្លើយតែងតែឈ្លោះប្រកែកគ្នា រស់នៅអស់មនោសញ្ចេតនាដែលមិនអាចរស់នៅជាមួយគ្នាបន្តទៀតបាន។ ដូចនេះ គប្បីតុលាការសម្រេចតាមការប្តឹងសុំរបស់ដើមចោទ តាមមូលហេតុទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមនឹងអាចបង្កើតឡើងវិញបាន ដោយ ផ្អែកតាមមាត្រា ៩៧៨ ក្រមរដ្ឋប្បវេណី។

២.២.ស្តីពីការទាមទារទី ២ : ការសុំគ្រប់គ្រងកូន

-តាមការអះអាងរបស់ដើមចោទ ឃើញថា ដើមចោទ និងចុងចម្លើយពិតជាមានកូនឈ្មោះ សារិន កិសុទ្ធ ភេទប្រុស កើតថ្ងៃទី១២.០១.២០១៩ តាមសំបុត្រកំណើត លេខ ២៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ របស់មន្ត្រីអត្រានុកូលដ្ឋាន ពិតប្រាកដមែន ។

-តាមការអះអាងរបស់ដើមចោទ ឃើញថា ដើមចោទបានស្នើសុំសិទ្ធិចិញ្ចឹម និងសិទ្ធិគ្រប់គ្រងថែរក្សាកូន ឈ្មោះ [redacted] កិសុទ្ធ ភេទប្រុស កើតថ្ងៃទី១២.០១.២០១៩ តាមសំបុត្រកំណើត លេខ ២៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ របស់មន្ត្រីអត្រានុកូលដ្ឋាន។ ដូចនេះ គប្បីតុលាការសម្រេចចេញសាលក្រមឲ្យដើមចោទជាអ្នកមានអំណាចមេបាលើកូន ដោយផ្អែកតាមមាត្រា ១០៣៧ ចំណុចទី១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

២.៣.ស្តីពី: អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

-តាមមាត្រា ៩៥០ ក្រមរដ្ឋប្បវេណី នារី(ដើមចោទ)ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ (មួយរយម្ភៃ) ថ្ងៃ ពុំទាន់បានកន្លងផុត គប្បីតុលាការសម្រេចពីករណីនេះ។

២.៤.ស្តីពីការទាមទារទី ៣ : អំពីសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន

-តាមការអះអាងរបស់ដើមចោទ បានអះអាងថា ខ្លួនសុំទាមទារសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាពរបស់ចុងចម្លើយ។ ដូចនេះ ដើម្បីជាប្រយោជន៍ និងអនាគតកូន និងដើម្បីជាធនធានមនុស្សដ៏ល្អរបស់សង្គមខ្មែរ គប្បីតុលាការសម្រេចអំពីសោហ៊ុយចាំបាច់ ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាពរបស់ដើមចោទរហូតដល់កូនមាននីតិភាព តាមមាត្រា ១០៤០ ក្រមរដ្ឋប្បវេណី។

២.៥.អំពីទ្រព្យសម្បត្តិរួម

-តាមការអះអាងរបស់ដើមចោទ ឃើញថា ដើមចោទ និងចុងចម្លើយមិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមជាមួយនឹងគ្នាទេ តប្បីតុលាការមិនពិចារណាលើការបែងចែកទ្រព្យរួម ឡើយ។

**៤.៦.អំពីប្រាក់ប្រដាប់ក្តី**

-ចំពោះប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ៣.ផ្នែកសម្រេចសេចក្តី

៣.១. ទទួលស្គាល់ពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២១ របស់ដើមចោទ ដោយបង្គាប់ឲ្យដើមចោទឈ្មោះ [redacted] ស្រីពូន ភេទស្រី កើតថ្ងៃទី១៤.០២.១៩៩០ លែងលះ ពីចុងចម្លើយឈ្មោះ [redacted] សារិន ភេទប្រុស កើតថ្ងៃទី០៣.០៨.១៩៩០ ចាប់ពីពេលនេះតទៅ ។

៣.២. ឲ្យដើមចោទស្ថិតក្នុងភាពមេម៉ាយរយៈពេល ១២០ (មួយរយម្ភៃ)ថ្ងៃ ។

៣.៣.ប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] ភិសុទ្ធ ភេទប្រុស កើតថ្ងៃទី១៤.០១.២០១៩ ឲ្យទៅដើមចោទឈ្មោះ [redacted] ស្រីពូន ជាអ្នកគ្រប់គ្រង រហូតដល់នីតិភាព។ ទុកសិទ្ធិឲ្យភាគីចុងចម្លើយដែលពុំបានថែរក្សាកូនអាចប្រាស្រ័យទាក់ទងជាមួយកូនតាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងបង្គាប់ឲ្យចុងចម្លើយបង់ប្រាក់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនឱ្យតាមលទ្ធភាពរហូតដល់នីតិភាព។

៣.៤. ប្រាក់ប្រដាក់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១។

ទុកសិទ្ធឲ្យគូភាគីប្តឹងឧបាស្រ័យតាមកំណត់ច្បាប់ ។

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ខេត្តព្រះសីហនុ,ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមប្រធានជំនុំជម្រះ**

[redacted]



Scanned with CamScanner